## Article IV

## Communication

To facilitate communication and implement the work planned in the memorandum, the National Committee for Counter Trafficking has designated Lieutenant Colonel Ron Sopheakpagna, Deputy Chief of the Planning Office, telephone number +(855)85585152 and email pagna.kh@ncct.gov.kh, as the focal point, and Caritas Switzerland has designated Mr. Kham Syngoun, Deputy Country Director, telephone number +(855)12985796 and email syngoun@caritas.ch, as the focal point to communicate in cooperation and implement the memorandum.

Changes in contact information must be made in writing and acknowledged by both parties.

## Article V

## Dispute Resolution

Any disputes arising from the interpretation or implementation of this Memorandum of Understanding shall be resolved through negotiations and consultations with mutual understanding between the National Committee for Counter Trafficking and Caritas Switzerland.

## Article V

## Entry into Force and Termination

This MoU may be terminated by either party upon 60 days written notice to the other party.

This MoU is made in two originals in the Khmer and English languages, both texts being equally authentic.

This MoU shall enter into force on the date of its signature.

This MoU shall be valid for a period of three (3) years and may be renewed upon mutual agreement of the Parties.

This MoU shall not create any additional rights or obligations.

Signed on Phnom Penh, Date 21/01/2025 in two originals in the English language.

| **Represent of National Committee for Counter Trafficking (NCCT)** | **Represent of Caritas Switzerland** |
| --- | --- |
| ………………………… | ………………………… |
| **H.E. CHOU BUN ENG** | **Sonja Loosli** |
| Permanent Vice Chair | Country Director |
| | ………………………… |
| | **Kham Syngoun** |
| | Deputy Country Director |

Kingdom of Cambodia
Nation Religion King

# Memorandum of Understanding

## Between

## NATIONAL COMMITTEE FOR COUNTER TRAFFICKING

## (NCCT)

## And

## CARITAS SWITZERLAND (CACH)

## On

**Actions to fight human trafficking and other exploitative forms of migration**

**2025-2027**

## Preamble

The National Committee for Counter Trafficking and Caritas Switzerland, hereinafter referred to as the "Parties".

Whereas the "Parties" intend to cooperate in humanitarian work in the Kingdom of Cambodia in order to contribute to the promotion of social well-being by ensuring the effectiveness of prevention and combating activities against human trafficking and other forms of exploitation in migration.

Whereas CARITAS SWITZERLAND (CACH) respects national and international law as well as the fundamental principles of independence, sovereignty, territorial integrity and non-interference in the internal affairs of the Kingdom of Cambodia. All activities will be carried out through national and sub-national mechanisms based on national and international laws, policies, and the National Strategic Plan on Combating Human Trafficking 2024-2028, as well as relevant legal instruments.

Whereas the "Parties" shall, on the basis of mutual interests and the needs of each Party, cooperate to protect and integrate migration and prevent the counter trafficking through the partnership agreement as set out in the Memorandum of Understanding.

Respecting the laws and legal norms of the Kingdom of Cambodia.

The Parties agree as follows:

## Article I

## Purpose

To combat human trafficking and other forms of exploitation in migration, through a comprehensive approach that includes prevention, protection, reintegration services and stakeholder coordination, to create a safer environment for vulnerable populations, especially women, children and youth, who are protected from exploitation and can contribute positively to society.

## Article II

## The responsibilities of the National Committee for Counter Trafficking

The National Committee for Counter Trafficking has the following responsibilities:

- Coordinate and provide support to the missions of Caritas Switzerland and other partner organizations in carrying out their work in accordance with the laws of the Kingdom of Cambodia.
- Coordinate with the provincial or sub-national Counter Trafficking Committees in participating in the activities of Caritas Switzerland and partner organizations to achieve the results stated above.

- Promote collaboration to support the multi-functional operation of the Kamrieng Migrant Reception Center to become a model center for the establishment of centers in other locations.
- Lead consultation meetings with stakeholders at the provincial level, including Banteay Meanchey and Battambang provinces, to coordinate stakeholders in addressing unsafe migration and combating human trafficking.
- Share information, good experiences and achievements at the national and sub-national levels for the benefit of communication and to enhance the effectiveness of work in preventing, protecting and integrating vulnerable and trafficked migrants and children.

## Article III

## Caritas Switzerland (CACH) has the responsibilities as follow:

Caritas Switzerland has the following responsibilities:

- Manage the program budget for the effective and efficient implementation of project activities and strictly comply with the laws and regulations of the Kingdom of Cambodia, not allowing its staff and partner organizations to engage in any activities that may affect safety, stability and social order or other activities that may harm national security, national unity, culture and traditions of the Cambodian people.
- Responsible for project management, supporting the protection of vulnerable migrant workers and children at risk of human trafficking, in accordance with its action plan and policy, adhering to the principles of cooperation set out in this Memorandum of Understanding.
- Strengthening the partnership between the National Committee for Counter Trafficking in all agreed activities and the provision of information and education to target groups. Exchange information between the national and sub-national levels regarding human trafficking and safe migration and provide annual standard reports in accordance with the government's reporting format to the National Committee for Counter Trafficking.
- Focus on activities related to safe migration and the counter human trafficking, avoiding any activities related to politics. Furthermore, there is no financial gain from the activities related to migrant workers.
- Notify the National Committee for Counter Trafficking in writing of any changes in address, representative and designated project person responsible.
- Project summary, goals, intervention activities, objectives and results of Caritas Switzerland are attached in Annex (1) and Annex (2).

អនុស្សរណៈនេះធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដោយអត្ថបទទាំងពីរមានតម្លៃស្មើគ្នា ។

អនុស្សរណៈនៃការយោគយល់គ្នានេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អនុស្សរណៈនៃការយោគយល់គ្នានេះ មានសុពលភាពរយៈពេលចំនួន បី( ០៣ )ឆ្នាំ និងអាចបន្តជាថ្មីបាន ក្នុងករណីមានការឯកភាពគ្នារវាងគូភាគី ។

អនុស្សរណៈនៃការយោគយល់នេះនឹងមិនមានការបង្កើតសិទ្ធិ និងកាតព្វកិច្ចបន្ថែមណាមួយឡើយ។

ចុះហត្ថលេខានៅ...ភ្នំពេញ. ថ្ងៃ២១ ខែមករា ឆ្នាំ២០២៥. ជា០២ច្បាប់ដើម ជាភាសាខ្មែរ។

**តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

**តំណាងអង្គការការីតាសស្វីស**
( CARITAS SWITZERLAND )
**នាយកប្រចាំប្រទេស**

CARITAS Schweiz 6002 Luzern Switzerland Suiza Svizzera Suisse

**ស៊ីនញ៉ា ឡូស្តី**

**នាយករងប្រចាំប្រទេសកម្ពុជា**

**ខាំ ស៊ីខួន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់

រវាង

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

និង

អង្គការការីតាសស្វីស (CARITAS SWITZERLAND)

ស្តីពី

សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទម្រង់
ផ្សេងទៀត នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក

២០២៥-២០២៧

## បុព្វកថា

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការការីតាសស្វីស ដែលតទៅនេះកំណត់ថា "គូភាគី"។

ដោយហេតុថា គូភាគី មានបំណងធ្វើកិច្ចសហប្រតិបត្តិការ លើការងារមនុស្សធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកលើកកម្ពស់ សុខុមាលភាពសង្គម ដោយធានាប្រសិទ្ធភាពការងារបង្ការទប់ស្កាត់ សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទម្រង់ផ្សេងទៀត នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក ។

ដោយហេតុថា អង្គការការីតាសស្វីស (CARITAS SWITZERLAND) គោរពច្បាប់ជាតិ និងច្បាប់អន្តរជាតិ ព្រមទាំងមូលដ្ឋានគ្រឹះ នៃឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពទាំងឡាយនឹង ត្រូវធ្វើឡើងតាមរយៈយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ផ្អែកលើច្បាប់ គោលនយោបាយជាតិ អន្តរជាតិ និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៤-២០២៨ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ដោយហេតុថា គូភាគី ត្រូវឈរលើមូលដ្ឋាន នៃផលប្រយោជន៍ទៅវិញទៅមក និងតម្រូវការរបស់ភាគីនីមួយៗ ក្នុងការសហការដើម្បីបង្ការទប់ស្កាត់ ការពារ និងធ្វើសមាហរណកម្ម លើការធ្វើចំណាកស្រុក និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈកិច្ចព្រមព្រៀងក្នុងភាពជាដៃគូដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់ ។

ដោយគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជា ។

គូភាគី បានព្រមព្រៀងគ្នាដូចតទៅ៖

## ប្រការ១

## គោលបំណង

ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទម្រង់ផ្សេងទៀត នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុកតាមរយៈវិធីសាស្ត្រដ៏ទូលំទូលាយមួយ ដែលរួមមានការបង្ការ ការការពារ សេវាធ្វើសមាហរណកម្មឡើងវិញ និងការសម្របសម្រួលភាគីពាក់ព័ន្ធ ដើម្បីបង្កើតបរិយាកាសសុវត្ថិភាពឱ្យកាន់តែប្រសើរឡើង ដល់ប្រជាជនងាយរងគ្រោះ ជាពិសេសស្ត្រី កុមារ និងយុវជន ដែលត្រូវបានការពារពីការកេងប្រវ័ញ្ច និងអាចរួមចំណែកផ្តល់ផលជាវិជ្ជមានដល់សង្គមជាតិ ។

## ប្រការ២

## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងផ្តល់ការគាំទ្របេសកកម្មរបស់ អង្គការការីតាសស្វីស (CARITAS SWITZERLAND) និងអង្គការដៃគូដទៃទៀតក្នុងការបំពេញការងាររបស់ខ្លួនស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។
- សម្របសម្រួលជាមួយ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត ឬថ្នាក់ក្រោមជាតិ ក្នុងការចូលរួមសហការសកម្មភាពនានារបស់ អង្គការការីតាសស្វីស (CARITAS SWITZERLAND) និងអង្គការដៃគូ ដើម្បីសម្រេចលទ្ធផលដូចមានចែងខាងលើ ។
- ជំរុញកិច្ចសហការដើម្បីគាំទ្រ កិច្ចប្រតិបត្តិការមណ្ឌលទទួលពលករកំរៀងដែលមានពហុមុខងារឱ្យក្លាយជាមណ្ឌលគំរូ សម្រាប់ការបង្កើតមណ្ឌលនៅទីតាំងផ្សេងទៀត ។
- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត រួមមាន ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ដើម្បីសម្របសម្រួលអ្នកពាក់ព័ន្ធក្នុងការដោះស្រាយការចំណាកស្រុកដោយប្រថុយប្រថាន និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- ចែករំលែកព័ត៌មាន បទពិសោធន៍ល្អៗ និងលទ្ធផលសម្រេចបាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជាប្រយោជន៍ សម្រាប់ការទំនាក់ទំនង និងលើកស្ទួយប្រសិទ្ធភាពការងារក្នុងការបង្ការទប់ស្កាត់ ការការពារ និងការធ្វើសមាហរណកម្មជនចំណាកស្រុក និងកុមារដែលងាយរងគ្រោះ និងដែលត្រូវបានគេជួញដូរ ។

## ប្រការ៣

## ការទទួលខុសត្រូវរបស់អង្គការការីតាសស្វីស (CARITAS SWITZERLAND)

អង្គការការីតាសស្វីស (CARITAS SWITZERLAND) មានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងថវិកាកម្មវិធី សម្រាប់ការអនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលចំគោលដៅ និងត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលមានជាធរមាន របស់ព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុញ្ញាតឱ្យបុគ្គលិក និងអង្គការដៃគូរបស់ខ្លួនចូលរួមនូវរាល់សកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀត ដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា ។
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោង គាំទ្រកិច្ចការពារសុវត្ថិភាពទេសន្តរប្រវេសន៍ការងារដែលងាយរងគ្រោះដោយចំណាកស្រុក និងកុមារដែលប្រឈមនឹងអំពើជួញដូរមនុស្ស ស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគោលការណ៍ នៃកិច្ចសហប្រតិបត្តិការដែលមានចែងនៅក្នុងអនុស្សរណៈ នៃការយោគយល់នេះ ។
- ពង្រឹងភាពជាដៃគូរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នូវរាល់សកម្មភាពដែលបានឯកភាពគ្នា និងការផ្តល់ព័ត៌មាន អប់រំដល់ក្រុមគោលដៅ។ ផ្លាស់ប្តូរព័ត៌មានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាក់ទងនឹងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយ

សុវត្ថិភាព ព្រមទាំងផ្តល់របាយការណ៍ស្តង់ដារប្រចាំឆ្នាំ តាមទម្រង់របាយការណ៍របស់រដ្ឋាភិបាល ទៅកាន់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

- ផ្តោតលើសកម្មភាពទាក់ទងនឹងការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយត្រូវចៀសវាងរាល់សកម្មភាពទាក់ទងនឹងនយោបាយ ប្រាក់ចំណូល និងចំណេញពីសកម្មភាពការងារចំណាកស្រុក ។
- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន អ្នកតំណាង និង អ្នកគ្រប់គ្រងគម្រោង។
- សេចក្តីសង្ខេបនៃគម្រោង គោលដៅ សកម្មភាពអន្តរាគមន៍ គោលបំណង និងលទ្ធផលនៃការីតាសស្វីស ត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ (1) និងឧបសម្ព័ន្ធ (2) ។

## ប្រការ៤

## ការទំនាក់ទំនង

ដើម្បីសម្រួលដល់ទំនាក់ទំនង និងអនុវត្តការងារតាមការគ្រោងទុក នៃអនុស្សរណៈនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចាត់តាំងលោក វរសេនីយ៍ទោ រ៉ែន សុភ័ក្រ្តបញ្ញា តួនាទី នាយរងការិយាល័យ សរុបផែនការ ទូរស័ព្ទទំនាក់ទំនង +(៨៥៥)៨៥៥៨៥១៥២ និងអ៊ីមែល pagna.kh@ncct.gov.kh ជាជនបង្គោល និងអង្គការការីតាសស្វីស ( CARITAS SWITZERLAND) ចាត់តាំងលោក ខាំ ស៊ីងួន នាយករងប្រចាំប្រទេស ទូរស័ព្ទលេខ +(៨៥៥)១២៩៨៥៧៩៦ និង អ៊ីម៉ែល syngoun@caritas.ch ជាជនបង្គោល ដើម្បីទំនាក់ទំនងក្នុងកិច្ចសហការអនុវត្តអនុស្សរណៈ ។

ការកែប្រែព័ត៌មានទំនាក់ទំនង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានការទទួលស្គាល់ដោយគូភាគី។

## ប្រការ៥

## ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពីការបកស្រាយ ឬការអនុវត្តនៃកិច្ចព្រមព្រៀងអនុស្សរណៈនេះ ត្រូវដោះស្រាយតាមរយៈការចរចា និងប្រឹក្សាយោបល់ប្រកបដោយការយោគយល់គ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការការីតាសស្វីស (CARITAS SWITZERLAND) ។

## ប្រការ៦

## ការចូលជាធរមាន និងការបញ្ចប់

អនុស្សរណៈនៃការយោគយល់នេះ អាចបញ្ចប់ដោយភាគីណាមួយក៏បាន គឺបន្ទាប់ពី ៦០ថ្ងៃ ដែលភាគីនោះផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជូនទៅភាគីម្ខាងទៀត។